# លោក ស្វាយ សារ៉េត អតីតជនភៀសខ្លួនកម្ពុជា ឈ្នះពានរង្វាន់សិល្បករថ្មីល្អបំផុត ក្នុងកម្មវិធី PRUDENTIAL EYE AWARD ឆ្នាំ២០១៦




**សិង្ហបុរី (ថ្ងៃអង្គារ ទី២០ ខែមករា ឆ្នាំ២០១៦)** - លោក ស្វាយ សារ៉េត បានទទួលពានរង្វាន់សិល្បករថ្មីល្អបំផុត (Overall Best Emerging Artist) នៅក្នុងកម្មវិធី Prudential Eye Awards ឆ្នាំ២០១៦ សម្រាប់សិល្បៈអាស៊ីសហសម័យ ។ លោក ស្វាយ សារ៉េត នឹងទទួលបានទឹកប្រាក់រង្វាន់សរុប ៥ម៉ឺនដុល្លារអាមេរិក និងទទួលបានឱកាសបង្ហាញស្នាដៃសិល្បៈរបស់គាត់ នៅក្នុងកម្មវិធីតាំងពិព័រណ៍ START Art Fair នៅវិចិត្រសាល Saatchi ដ៏ល្បីល្បាញនៅក្នុងឆ្នាំនេះទៀតផង ។

លោក ស្វាយ សារ៉េត កើតក្នុងឆ្នាំ១៩៧២ និងមានស្រុកកំណើតនៅខេត្តបាត់ដំបង ប្រទេសកម្ពុជា ។ ក្នុងឆ្នាំ ១៩៧៩ លោក និងក្រុមគ្រួសារ បានរត់ទៅរស់នៅក្នុងជំរំជនភៀសខ្លួន តាមព្រំដែនថៃ ដោយគាត់រស់នៅទីនោះអស់រយៈពេល ១៣ឆ្នាំ ។ នៅទីនោះ លោក ស្វាយ សារ៉េត បានជួបនឹងគ្រូស្ម័គ្រចិត្ត ជនជាតិបារាំងម្នាក់ ដែលមកបង្រៀនសិល្បៈដល់អ្នករស់នៅជំរំ ហើយក៏បានរៀនសូត្រពីរបៀបគូរគំនូរពីគាត់ ។ កិច្ចការសិល្បៈរបស់លោក ស្វាយ សារ៉េត បានចាប់ផ្តើមតាំងពីពេលគាត់រស់នៅក្នុងជំរំជនភៀសខ្លួន ហើយស្នាដៃរបស់គាត់ឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រសង្គម និងនយោបាយនៃប្រទេសកម្ពុជា តាមរយៈរូបចម្លាក់ ការសម្តែង និងសិល្បៈដំឡើង ។ គាត់លាតត្រដាងប្រវត្តិសាស្ត្រប្រទេសកម្ពុជា តាមរយៈសិល្បៈកំណាព្យ និងការវិនិច្ឆ័យផ្ទាល់ខ្លួន ។

លោក Niru Ratnam នាយកកម្មវិធី Prudential Eye Programme បានមានប្រសាសន៍ថា "សាច់រឿងរបស់ លោក ស្វាយ សារ៉េត គឺជាសាច់រឿងដ៏អស្ចារ្យ និងគួរឲ្យកោតសរសើរ ។ ស្នាដៃសិល្បៈរបស់លោក ឆ្លុះបញ្ចាំងនូវបរិបទដ៏ជាក់លាក់មួយ តែមានលក្ខណៈអស្ចារ្យលើសពីធម្មតា ។ គាត់បានបង្កើតស្នាដៃសិល្បៈ ដែលមានភាពកំប្លែង តែពោរពេញដោយសិល្បៈកំណាព្យ និងជំនឿចិត្ត ។ គាត់ពិតជាសក្តិសមនឹងឈ្នះពានរង្វាន់ពីកម្មវិធី Prudential Eye Awards ។"

PRUDENTIAL EYE AWARDS
CONTEMPORARY ASIAN ART

លោកស្រី Grace Fu រដ្ឋមន្ត្រីក្រសួងវប្បធម៌ សហគមន៍ និងយុវជន ប្រទេសសឹង្ហបុរី បានមានប្រសាសន៍ថា "កម្មវិធី Prudential Eye Awards គឺជាគំនិតផ្តួចផ្តើមរវាងវិស័យសាធារណៈ និងវិស័យឯកជន ដែលផ្តល់ពានរង្វាន់ដល់សិល្បករសហសម័យ និងសិល្បករថ្មីៗនៅអាស៊ី ។ សិល្បៈសហសម័យនៅក្នុងតំបន់អាស៊ី កំពុងរីកលូតលាស់ជាលំដាប់ ហើយសិល្បករ-សិល្បការិនីវ័យក្មេងក្នុងតំបន់ជាច្រើន មានស្នាដៃល្អៗដែលអាចយកមកបង្ហាញដល់សាធារណជនសិង្ហបុរី ។ កម្មវិធីតាំងពិព័រណ៍ និងប្រគល់ពានរង្វាន់នេះ គឺជាលទ្ធផលនៃការចូលរួមយ៉ាងសកម្មរបស់វិស័យសាជីវកម្ម ដែលផ្តល់ឱកាសឱ្យយើងមើលឃើញពីតម្លៃនៃស្នាដៃរបស់សិល្បករទាំងនេះ តាមរយៈការនាំយកនូវស្នាដៃរបស់ពួកគេមកតាំងបង្ហាញក្នុងប្រទេសសិង្ហបុរី ។ ការគាំទ្ររបស់វិស័យឯកជន ពិតជាមានសារៈសំខាន់យ៉ាងខ្លាំង ដល់ការអភិវឌ្ឍវិស័យសិល្បៈក្នុងប្រទេសសិង្ហបុរី ។ បរិយាកាសរឹងមាំក្នុងវិស័យសិល្បៈ គឺជាកត្តាដ៏ចាំបាច់ក្នុងការសំរេចគោលដៅរបស់យើង ដែលចង់ក្លាយជាទីក្រុងវប្បធម៌ដ៏រស់រវើកមួយ ។"

លោក Sean Rach ប្រធានផ្នែកទីផ្សារ សាជីវកម្មព្រូដិនសលអាស៊ី បានមានប្រសាសន៍ថា "ក្រុមហ៊ុនព្រូដិនសល មានប្រវត្តិគាំទ្រដល់សិល្បៈសហសម័យតាំងតែពីដើមមក ហើយយើងមានមោទនភាព ដោយបានរៀបចំប្រគល់ពានរង្វាន់ Prudential Eye Awards នៅក្នុងប្រទេសសិង្ហបុរី រយៈពេលបីឆ្នាំជាប់គ្នា ។ ស្នាដៃរបស់សិល្បៈករទាំងនេះ ឆ្លុះបញ្ចាំងឲ្យយើងឃើញនូវបេះដូង និងដួងព្រលឹងនៃតំបន់ដ៏រស់រវើកមួយនេះ ហើយយើងសង្ឃឹមថា ពានរង្វាន់នេះនឹងជួយលើកកម្ពស់ពួកគេឲ្យទទួលបានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ កាន់តែអស្ចារ្យ ក៏ដូចជាលើកកម្ពស់ការយល់ដឹង និងការកោតសរសើរចំពោះសិល្បៈ និងវប្បធម៌អាស៊ីសហសម័យ ជាសកលបន្ថែមទៀត ។"

ដោយបានចាប់ផ្តើមឡើងក្នុងឆ្នាំ២០១៤ កម្មវិធីប្រចាំឆ្នាំនេះដ៏មានកិត្យានុភាពនេះ ផ្តល់ពានរង្វាន់ដល់សិល្បករថ្មីៗល្អបំផុតនៅអាស៊ី ក៏ដូចជាផ្តល់ពានរង្វាន់ដល់កម្មវិធីតាំងពិព័រណ៍ វិចិត្រសាល ស្ថាប័នសិល្បៈ និងអ្នកវាយតម្លៃសិល្បៈឈានមុខគេសំដៅលើកកម្ពស់សិល្បៈសហសម័យក្នុងតំបន់អាស៊ី ។

ក្នុងឆ្នាំទីបីនេះ កម្មវិធី Prudential Eye Awards ផ្តល់ពានរង្វាន់ដល់សិល្បៈថ្មីល្អបំផុត សម្រាប់ប្រភេទសិល្បៈចំនួន៥ គឺសិល្បៈឌីជីថល/វីដេអូ សិល្បៈដំឡើង សិល្បៈគំនូរ រូបថត និងរូបចម្លាក់ ។ លោកស្រី Grace Fu រដ្ឋមន្ត្រីក្រសួងវប្បធម៌ សហគមន៍ និងយុវជន ប្រទេសសឹង្ហបុរី បានចូលរួមជាគណអធិបតីក្នុងកម្មវិធីប្រគល់ពានរង្វាន់ឆ្នាំ២០១៦ នេះ ដែលប្រារព្ធឡើងជាផ្នែកនៃព្រឹត្តិការណ៍ "សប្តាហ៍សិល្បៈសឹង្ហបុរី" (Singapore Art Week) ហើយលោកស្រី ក៏បានផ្តល់កិត្តយសធ្វើជាអ្នកប្រកាសឈ្មោះអ្នកឈ្នះរង្វាន់ធំបំផុត (Overall Winner) ក្នុងកម្មវិធីផងដែរ ។

អមជាមួយកម្មវិធីប្រគល់ពានរង្វាន់នេះផងដែ គឺការតាំងពិព័រណ៍ជាសាធារណៈនៅសារមន្ទីរ ArtScience ប្រទេសសឹង្ហបុរី ដែលចាប់ផ្តើមពីថ្ងៃទី១៦ ខែមករា ដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៦ ។ ការតាំងពិព័រណ៍នេះ នឹងតាំងបង្ហាញស្នាដៃសិល្បៈចំនួន៣៩ របស់សិល្បករជាប់ឈ្មោះបឋម (shortlisted) ទាំង១៥នាក់ ក្នុងកម្មវិធី Prudential Eye Awards សម្រាប់ប្រភេទសិល្បៈ ដូចតទៅ៖ សិល្បៈឌីជីថល/វីដេអូ សិល្បៈដំឡើង សិល្បៈគំនូរ រូបចម្លាក់ និងរូបថត ។ នេះគឺជាលើកទីពីរ ហើយ ដែលសណ្ឋាគារ Marina Bay Sands ត្រូវបានជ្រើសរើសជាទីតាំងសម្រាប់រៀបចំកម្មវិធីប្រគល់រង្វាន់ និងធ្វើការតាំងពិព័រណ៍នេះ ។

PRUDENTIAL
EYE AWARDS
CONTEMPORARY ASIAN ART

**សិល្បករឈ្នះពានរង្វាន់**

ក្រៅពីត្រូវបានជ្រើសរើសជាអ្នកឈ្នះរង្វាន់ធំបំផុត (Overall Winner) លោក ស្វាយ សារ៉េត ក៏ឈ្នះពានរង្វាន់សិល្បករថ្មីល្អបំផុត (Best Emerging Artist) សម្រាប់សិល្បៈចម្លាក់ផងដែរ ។

សិល្បករឈ្នះពានរង្វាន់ នឹងទទួលបានទឹកប្រាក់រង្វាន់ ២ម៉ឺនដុល្លារអាមេរិក ក្នុងម្នាក់ នៅក្នុងកម្មវិធីប្រគល់រង្វាន់កម្រិតអន្តរជាតិ នៅសាលមហោស្រព MasterCard Theatres - Sands Theatre នៃសណ្ឋាគារ Marina Bay Sands ប្រទេសសិង្ហបុរី ។

ឈ្មោះ Huang Po Chih (កោះតៃវ៉ាន់) ឈ្នះពានរង្វាន់សិល្បករថ្មីល្អបំផុត សម្រាប់សិល្បៈដំឡើង ។

ឈ្មោះ Manish Nai (ប្រទេសឥណ្ឌា) ឈ្នះពានរង្វាន់សិល្បករថ្មីល្អបំផុត សម្រាប់សិល្បៈគំនូរ ។

ឈ្មោះ Shumon Ahmed (ប្រទេសបង់ក្លាដេស) ឈ្នះពានរង្វាន់សិល្បករថ្មីល្អបំផុត សម្រាប់សិល្បៈរូបថត ។

ឈ្មោះ Trinh Thi Nguyen (ប្រទេសវៀតណាម) ឈ្នះពានរង្វាន់សិល្បករថ្មីល្អបំផុត សម្រាប់សិល្បៈឌីជីថល/វីដេអូ ។

**អ្នកឈ្នះពានរង្វាន់ផ្សេងៗទៀត**

សិល្បករដ៏ល្បីឈ្មោះរបស់ថៃ លោក Sakarin Krue-On បានទទួលពានរង្វាន់មួយជីវិត សម្រាប់សិល្បៈអាស៊ីសហសម័យ ។ ស្នាដៃរបស់គាត់ តែងបានឆ្លុះបញ្ចាំងនូវប្រពៃណីទំនៀមទំលាប់របស់ប្រទេសថៃ ក្នុងបែបហសម័យ និងផ្តោតទៅលើក្តីបារម្ភរបស់លោកនៅក្នុងតំបន់អាស៊ី ។ លោក Sakarin Krue-On ធ្លាប់តាំងបង្ហាញស្នាដៃរបស់ខ្លួននៅក្នុងសារមន្ទីរ Venice Biennale (ពីរដង) និងសារមន្ទីរ Documenta ជាសារមន្ទីរលំដាប់អន្តរជាតិ ដែលហាក់ដូចនឹងលោកបានចែករំលែកក្តីបារម្ភរបស់លោក នៅលើឆាកអន្តរជាតិផងដែរ ។

ពានរង្វាន់សម្រាប់សិល្បៈបង្ហាញ និងវប្បធម៌ផប (Visual & Pop Culture) គឺជាពានរង្វាន់ដែលប្រគល់ទៅដល់ស្នាដៃដែលលើសពីសិល្បៈ និងបង្ហាញនូវលក្ខណៈទំនើប ហើយពានរង្វាន់នេះបានប្រគល់ទៅដល់ក្រុមចម្រៀងរ៉ុក របស់ប្រទេសថៃ ឈ្មោះថា Slot Machine ដែលល្បីខាងសំឡេងបែបថៃជាពិសេស រួមផ្សំនឹងការប្រើបទភ្លេង ហ្គីតា និងការច្រៀង ដែលយកលំនាំពីភ្លេងប្រពៃណីថៃ ។

អ្នកឈ្នះពានរង្វាន់ផ្សេងទៀត ដែលត្រូវបានប្រកាសនៅក្នុងកម្មវិធីនេះ គឺវិទ្យាស្ថាន Spring Workshop (ទីក្រុងហុងកុង) ដែលទទួលបាន "ពានរង្វាន់វិទ្យាស្ថានសិល្បៈអាស៊ីសហសម័យល្អបំផុត" និងកម្មវិធីតាំងពិព័រណ៍សិល្បៈ "Great Crescent: Art and Agitation in the 1960s – Japan, South Korea and Taiwan" រៀបចំដោយមជ្ឈមណ្ឌលសិល្បៈ Para Site (ទីក្រុងហុងកុង) ដែលទទួលបានពានរង្វាន់ ការតាំងពិព័រណ៍សិល្បៈអាស៊ីសហសម័យល្អបំផុត ។

ជាសរុបមក អ្នកឈ្នះពានរង្វាន់ក្នុងកម្មវិធី **Prudential Eye Awards ឆ្នាំ២០១៦** ទាំងអស់ មានដូចខាងក្រោម៖

១. សិល្បករថ្មីល្អបំផុតប្រចាំឆ្នាំ (Overall Emerging Artist of the Year)
ស្វាយ សារ៉េត (ប្រទេសកម្ពុជា)

២. អ្នកឈ្នះពានរង្វាន់សម្រាប់ សិល្បៈដំឡើង

Huang Po Chih ( កោះតៃវ៉ាន់ )

៣. អ្នកឈ្នះពានរង្វាន់សម្រាប់ សិល្បៈឌីជីថល/វីដេអូ
Trinh Thi Nguyen ( ប្រទេសវៀតណាម )

៤. អ្នកឈ្នះពានរង្វាន់សម្រាប់ សិល្បៈគំនូរ
Manish Nai ( ប្រទេសឥណ្ឌា )

៥. អ្នកឈ្នះពានរង្វាន់សម្រាប់ សិល្បៈរូបថត
Shumon Ahmed ( ប្រទេសបង់ក្លាដែស )

៦. អ្នកឈ្នះពានរង្វាន់សម្រាប់ សិល្បៈចម្លាក់
ស្វាយ សារ៉េត ( ប្រទេសកម្ពុជា )

៧. អ្នកឈ្នះពានរង្វាន់មួយជីវិត សម្រាប់សិល្បៈអាស៊ីសហសម័យ
Sakarin Krue-On ( ប្រទេសថៃ )

៨. អ្នកឈ្នះពានរង្វាន់ សម្រាប់សិល្បៈបង្ហាញ និងវប្បធម៌ផប ( Visual & Pop Culture )
ក្រុម Slot Machine ( ប្រទេសថៃ )

៩. អ្នកឈ្នះពានរង្វាន់ វិទ្យាស្ថានសិល្បៈអាស៊ីសហសម័យល្អបំផុត
វិទ្យាស្ថាន Spring Workshop ( ទីក្រុងហុងកុង )

១០. អ្នកឈ្នះពានរង្វាន់ ការតាំងពិព័រណ៍សិល្បៈអាស៊ីសហសម័យល្អបំផុត
កម្មវិធីតាំងពិព័រណ៍សិល្បៈ "Great Crescent: Art and Agitation in the 1960s – Japan, South Korea and Taiwan" រៀបចំដោយមជ្ឈមណ្ឌលសិល្បៈ Para Site ( ទីក្រុងហុងកុង )

###############

**សាកសួរព័តមានទូទៅ៖**
លោកស្រី Janice Fong
មជ្ឈមណ្ឌលសិល្បៈសហសម័យ Parallel
អ៊ីមែល៖ j.fong@parallelcontemporaryart.com

**សាកសួរព័ត៌មានដោយអ្នកសារព័ត៌មាន៖**
លោកស្រី Aly Ang
ក្រុមហ៊ុន W Communications
អ៊ីមែល៖ aly@wcommunications.sg

**អំពីកម្មវិធី Prudential Eye Awards**

**កម្មវិធី Prudential Eye Awards** ត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០១៤ ដោយកម្មវិធី Global Eye Programme ដែលផុសឡើងពីជាភាពជាដៃគូរវាងក្រុមហ៊ុនព្រូដិនសល មជ្ឈមណ្ឌលសិល្បៈសហសម័យ Parallel និងវិចិត្រសាល Saatchi ។ ព្រឹត្តិការណ៍ប្រគល់ពានរង្វាន់ប្រចាំឆ្នាំនេះ ផ្តោតជាសំខាន់លើសិល្បករថ្មីៗនៅទូទាំងមហាតំបន់អាស៊ី និងសំដៅឆ្លុះបញ្ចាំងនូវភាពសម្បូរបែបនៃស្នាដៃរបស់សិល្បករក្នុងតំបន់នេះ ។ ដោយសហការជាមួយ វិចិត្រសាល Saatchi កម្មវិធីនេះផ្តល់ឱកាសឲ្យសិល្បករថ្មីៗទាំងនេះ បានតាំងបង្ហាញស្នាដៃរបស់ខ្លួនដល់ទស្សនិកជន និងបានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ។ កម្មវិធីប្រគល់ពានរង្វាន់ Prudential Eye Awards លើកទីបី នឹងប្រព្រឹត្តិទៅនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ នៅប្រទេសសិង្ហបុរី ។ www.prudentialeyeawards.com

**អំពីចៅក្រមក្នុងកម្មវិធី Prudential Eye Awards**

លោកស្រី **Serenella Ciclitira** មានសញ្ញាប័ត្រកិត្តិយសប្រវត្តិសាស្ត្រសិល្បៈ ពីមហាវិទ្យាល័យ Trinity ទីក្រុង Dublin និងបានធ្វើការជាច្រើនជាមួយសិល្បករ និងវិចិត្រសាលនៅទូទាំងពិភពលោក ។ លោកស្រី រួមជាមួយនឹងស្វាមី គឺលោក David Ciclitira គឺជាសហស្ថាបនិកនៃកម្មវិធី Global Eye Programme និងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់កម្មវិធីនេះ ។ លោកស្រីបានក្លាយជាសមាជិកកិត្តិយសនៅរាជមហាវិទ្យាល័យសិល្បៈ នៃទីក្រុងឡុងដ៍ ហើយចាប់តាំងពីឆ្នាំ១៩៩០មក ជាអ្នកប្រគល់ពានរង្វាន់ Parallel Prize សម្រាប់សិល្បៈគំនូរ និងអាហារូបករណ៍ Serenella Ciclitira សម្រាប់សិល្បៈចម្លាក់ ។ លោកស្រី Gillian Carnegie ជាអតីតអ្នកឈ្នះពានរង្វាន់ Parallel Prize ម្នាក់ ត្រូវបានជ្រើសរើសសម្រាប់ពានរង្វាន់ Turner Prize ហើយលោក Benedict Carpenter និងលោក Gereon Krebber ដែលជាអតីតអ្នកឈ្នះពានរង្វាន់ Parallel Prize បានឈានទៅឈ្នះពានរង្វាន់ចម្លាក់អន្តរជាតិ Jerwood Sculpture Prize ដ៏ល្បីល្បាញ ។ ចំណែកលោក Martin Westwood ជាអតីតអ្នកឈ្នះពានរង្វាន់ Parallel Prize ម្នាក់ដែរ ត្រូវបានគេយកស្នាដៃទៅតាំងបង្ហាញក្នុងកម្មវិធីពិព័រណ៍សិល្បៈ Art Now នៅសារមន្ទីរ Tate Britain ក្នុងឆ្នាំ២០០៥ ។

លោក **Nigel Hurst** គឺជាប្រធាន និងអគ្គនាយកនៃវិចិត្រសាល Saatchi Gallery នៅទីក្រុងឡុង។ លោកបានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យ Goldsmith នៃសាកលវិទ្យាល័យ London University ក្នុងឆ្នាំ១៩៨៦ ហើយចាប់តាំងពីពេលនោះមក បានរៀបចំដឹកនាំការតាំងពិព័រណ៍អន្តរជាតិជាច្រើន ។ លោកបានចូលបម្រើការងារក្នុងវិចិត្រសាល Saatchi ក្នុងឆ្នាំ១៩៩៧ ក្នុងតំណែងជាអ្នកអភិរក្ស ដោយធ្វើការក្នុងផ្នែក Sensation នៃរាជបណ្ឌិតសភាសិល្បៈទីក្រុងឡុងដ៍ វិចិត្រសាលជាតិ Hamburger Bahnhof នៅទីក្រុងប៊ែកឡាំង និងសារមន្ទីរសិល្បៈ Brooklyn ក្នុងទីក្រុងញូវយ៉ក ។ ការតាំងពិព័រណ៍ជាច្រើន ផ្តោតសំខាន់លើសិល្បៈអាស៊ីសហសម័យ រួមទាំងព្រឹត្តិការណ៍ The Revolution Continues: New Art from China (ឆ្នាំ២០០៨) ព្រឹត្តិការណ៍ Unveiled: New Art from Middle East (ឆ្នាំ២០០៩) ព្រឹត្តិការណ៍ The Empire Strikes Back: Indian Art Today (២០១០) ព្រឹត្តិការណ៍ The Silk Road (ឆ្នាំ២០១១) ដោយសហការជាមួយទីក្រុង Lille ប្រទេសបារាំង និងព្រឹត្តិការណ៍ Korean Eye (ឆ្នាំ២០១២) ។ លោកក៏ជាសមាជិករបស់រាជការិយាល័យនៃទីក្រុង Kensington និងជាសមាជិកក្រុមប្រឹក្សាភិបាលសិល្បៈសាធារណៈទីក្រុង Chelsea ចាប់តាំងពីឆ្នាំ២០០៩ ដែលជាក្រុមប្រឹក្សាភិបាលមួយ ដែលប្រមូលផ្តុំទីប្រឹក្សាសម្រាប់ទីក្រុង Chelsea និងមន្ទីរពេទ្យ Westminster ព្រមទាំងជាសមាជិកក្រុមប្រឹក្សាអភិវឌ្ឍនៃសាកលវិទ្យាល័យសិល្បៈ ទីក្រុងឡុងដ៍ទៀតផង ។

លោក **Chang Tsong-Zung** (Johnson Chang) ជាអ្នកអភិរក្ស និងជាសាស្ត្រាចារ្យកិត្តយសបណ្ឌិតសភាសិល្បៈចិនប្រចាំទីក្រុង Hangzhou និងជានាយកនៃវិចិត្រសាល Hanart TZ និងជាសមាជិកក្រុមប្រឹក្សានៃបណ្ណសារសិល្បៈអាស៊ី និងសាលា Inter-Asia ។ លោកបានចូលរួមសកម្មក្នុងការរៀបចំតាំងការពិព័រណ៍ក្នុងប្រទេសចិន ចាប់តាំងពីទសវត្សរ៍ឆ្នាំ

១៩៨០ រួមមានដូចជាព្រឹត្តិការណ៍ China's New Art Post-1989 (ឆ្នាំ១៩៩៣-១៩៩៨) ការតាំងពិព័រណ៍ពិសេសនៅសារមន្ទីរ São Paulo Biennial ឆ្នាំ១៩៩៦ និងសារមន្ទីរ Venice Biennale ឆ្នាំ២០០១ ។ គម្រោងធំៗផ្សេងទៀតដែលលោកបានចូលរួម មានដូចជាព្រឹត្តិការណ៍ពិព័រណ៍ Power of the Word (តាំងពី ឆ្នាំ១៩៩៩) គម្រោងស្រាវជ្រាវអំពីសិល្បៈសម័យ និងប្រពៃណីចិន ហៅថា Yellow Box (តាំងពីឆ្នាំ២០០៤) ។ លោកក៏បានចូលរួមសហការក្នុងកម្មវិធី Guangzhou Triennial 2008 Farewell to Post-Colonialism ឆ្នាំ២០០៨ គម្រោង West Heavens projects of India-China art and social thought (តាំងពីឆ្នាំ២០១០) និងព្រឹត្តិការណ៍ 9th Shanghai Biennale (2012), Reactivation ។

លោក **Fumio Nanjo** ជានាយកនៃសារមន្ទីរសិល្បៈ Mori ចាប់ពីខែវិច្ឆិកា ឆ្នាំ២០០៦មក ។ លោកបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ Keio ជំនាញសេដ្ឋកិច្ច (ឆ្នាំ១៩៧២) និងសំណេរ (សោភ័ណវិទ្យា/ប្រវត្តិសាស្ត្រសិល្បៈ ឆ្នាំ១៩៧៧) ។ សមិទ្ធិផលសំខាន់របស់លោក រួមមាន ការកាន់តំណែងជាការស្នងការនៃកម្មវិធី Japan Pavilion at the Venice Biennale (ឆ្នាំ១៩៩៧) តំណែងជាការស្នងការនៃកម្មវិធី Taipei Biennale (ឆ្នាំ១៩៩៨) ជាសមាជិកគណៈកម្មាធិការគណៈវិនិច្ឆ័យពានរង្វាន់ Turner Prize (ឆ្នាំ១៩៩៨) ជានាយកផ្នែកសិល្បៈនៃព្រឹត្តិការណ៍ Yokohama Triennale ឆ្នាំ២០០១ ជាសមាជិកគណៈកម្មាធិការគណៈវិនិច្ឆ័យពានរង្វាន់ Golden Lion Prize នៃព្រឹត្តិការណ៍ Venice Biennale (ឆ្នាំ២០០៥) និងជានាយកផ្នែកសិល្បៈនៃព្រឹត្តិការណ៍ Singapore Biennale (ឆ្នាំ២០០៦/២០០៨) ។ លោកបានបោះពុម្ពផ្សាយ នូវសៀវភៅ Asian Contemporary Art Report: China, India, Middle East and Japan (២០១០) និងសៀវភៅ A Life with Art (ឆ្នាំ២០១២) ។

លោកស្រី Honor Harger ជានាយកប្រតិបត្តិនៃសារមន្ទីរ ArtScience នៅសណ្ឋាគារ Marina Bay Sands ។ មានប្រវត្តិជាអ្នកអភិរក្សមកពីប្រទេសនូវែលហ្សេឡង់ លោកស្រីមានការចាប់អារម្មណ៍យ៉ាងខ្លាំង ទៅលើការប្រើប្រាស់បច្ចេកវិទ្យា និងវិទ្យាសាស្ត្រប្រកបដោយសិល្បៈ និងដើម្បីវប្បធម៌ ។ លោកស្រី Honor Harger មានបទពិសោធន៍ជាង១៥ឆ្នាំ ក្នុងការធ្វើការនៅចំនុចប្រសព្វរវាងសិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ។ លោកស្រីគឺជាអ្នកទទួលខុសត្រូវចំពោះការកំណត់ទិសដៅរួម និងយុទ្ធសាស្ត្រសម្រាប់សារមន្ទីរ ArtScience ។ ក្នុងអាជីពរបស់លោកស្រី គាត់ធ្លាប់កាន់តំណែងសំខាន់ៗជាច្រើននៅក្នុងចក្រភពអង់គ្លេស ប្រទេសនូវែលហ្សេឡង់ និងប្រទេសអូស្ត្រាលី ហើយធ្លាប់បានដឹកនាំការតាំងពិព័រណ៍ និងព្រឹត្តិការណ៍អន្តរជាតិជាច្រើននៅជុំវិញពិភពលោក ។ ក្នុងឆ្នាំ២០០៩-២០១០ លោកស្រីគឺជាអ្នកអភិរក្សក្នុងកម្មវិធី Transmediale ដែលជាកម្មវិធីអន្តរជាតិ ផ្តោតលើសិល្បៈ និងវប្បធម៌ឌីជីថល នៅក្នុងទីក្រុងប៉ែកឡាំង ។ ក្នុងឆ្នាំ ២០០៤-២០០៨ លោកស្រី គឺជានាយកនៃកម្មវិធី AV Festival ដែលជាកម្មវិធីពិព័រណ៍សិល្បៈ ប្រព័ន្ធផ្សព្វផ្សាយ ខ្សែភាពយន្ត និងតន្ត្រីធំបំផុតនៅអង់គ្លេស ។ ក្នុងឆ្នាំ ២០០០-២០០៣ លោកស្រីគឺជាអ្នកអភិរក្សទីមួយរបស់សារមន្ទីរ Tate Webcast នៅទីក្រុងឡុងដ៍ ដែលលោកស្រីបានរៀបចំព្រឹត្តិការណ៍ និងការប្រគំតន្ត្រីទាក់ទងនឹងសិល្បៈ និងបច្ចេកវិទ្យាជាច្រើន ។

លោក **Gu Wenda** ជាម្ចាស់ពានរង្វាន់មួយជីវិត ឆ្នាំ២០១៥ ពីកម្មវិធី Prudential Eye Awards ។ ចាប់តាំងពីឆ្នាំ ១៩៨១ មក លោក Gu Wenda បានចូលរួមក្នុងការតាំងពិព័រណ៍ទោល និងការតាំងពិព័រណ៍អន្តរជាតិជាច្រើនរាប់មិនអស់ និងបានចូលរួមក្នុងកម្មវិធី Biennale នៅក្នុងប្រទេសជាង៣០ ផ្សេងគ្នា ។ គាត់ទទួលបានការតាំងពិព័រណ៍ស្នាដៃជាលើកដំបូងក្នុងអាជីពសិល្បៈរបស់លោក នៅឯវិចិត្រសាលជាតិនៃប្រទេសអូស្ត្រាលី ក្នុងឆ្នាំ២០០១-២០០២ ។ ការងារសិល្បៈរបស់លោក ត្រូវបានរក្សាទុកជាអចិន្ត្រៃយ៍នៅក្នុងសារមន្ទីរ Metropolitan សារមន្ទីរ Guggenheim សារមន្ទីរសិល្បៈទីក្រុងញូវយ៉ក សារមន្ទីរសិល្បៈទីក្រុងហុងកុង សារមន្ទីរសិល្បៈទំនើបទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ វិចិត្រសាលជាតិប្រទេសអូស្ត្រាលី និងសារមន្ទីរឯកជនជាច្រើនទៀត ។

លោកបណ្ឌិត Peter Selz បានហៅលោក Wenda Gu ថាជា "សិល្បករដើម និងល្អជាងគេនៅក្នុងប្រទេសចិន ចាប់តាំងពីសម័យបដិវត្តន៍មក។" លោកស្រី Roberta Smith ប្រចាំកាសែត New York Times បានសរសេរថា "លោក Wenda Gu ... គឺជាសិល្បករម្នាក់ ដែលការងាររបស់លោកមានសាធារណៈមួយចំនួនគិតថាមិនដូចជាសិល្បៈ តែមានមនុស្សជាច្រើនក្នុងវិស័យសិល្បៈការពារយ៉ាងក្លៀវក្លា ...។" លោក Edward Lucie-Smith បានសរសេរកាលពីពេលថ្មីៗនេះថា "លោក Wenda Gu គឺជាសិល្បករប្រកបដោយភាពច្នៃប្រឌិតបំផុត របស់ប្រទេសចិន នៅចុងទសវត្សឆ្នាំ១៩៨០ និង១៩៩០ ។ គាត់គឺជាបុគ្គលដែលល្បីសុសសាយលើឆាកអន្តរជាតិ ។ ជាពិសេស គាត់គឺជាបុគ្គលសំខាន់ម្នាក់ក្នុងវប្បធម៌បច្ចុប្បន្ននេះ ។"

លោកស្រី **Rosalyn D'Mello** គឺជាអ្នកនិពន្ធឯករាជ្យ មានមូលដ្ឋាននៅទីក្រុង New Delhi ដែលបានសរសេរអត្ថបទយ៉ាងច្រើនក្នុងវិស័យសិល្បៈ ។ លោកស្រីជានិពន្ធនាយកនៃទស្សនាវដ្តី BLOUIN ARTINFO នៃប្រទេសឥណ្ឌា ។ លោកស្រីផ្តល់អត្ថបទជាប្រចាំទៅដល់ទស្សនាវដ្តីធំៗ ដូចជាទស្សនាវដ្តី Vogue ទស្សនាវដ្តី Open ទស្សនាវដ្តី Mint Lounge និងទស្សនាវដ្តី Art Review Asia ។ លោកស្រីគឺជាអ្នកនិពន្ធម្នាក់ក្នុងចំណោមប្រាំនាក់ ដែលត្រូវបានតែងតាំងសម្រាប់ពានរង្វាន់ អ្នកនិពន្ធសិល្បៈថ្មីល្អបំផុត របស់ទស្សនាវដ្តី Forbes ក្នុងឆ្នាំ២០១៤ និងត្រូវបានតែងតាំងសម្រាប់ពានរង្វាន់អ្នកនិពន្ធល្អបំផុតអំពីសិល្បៈសហសម័យ របស់កម្មវិធី Prudential Eye Art Award ឆ្នាំ២០១៤ ។ លោកស្រីក៏ជានិពន្ធនាយករង នៃសៀវភៅ The Art Critic ជាសៀវភៅកម្រាស់ជាង ៦០០សន្លឹក ដែលវាយតម្លៃស្នាដៃសិល្បៈតាំងពីសម័យឆ្នាំ១៩៥០ របស់លោក Richard Bartholomew រហូតមកដល់សម័យឆ្នាំ១៩៨០ ។ សៀវភៅដំបូងរបស់លោកស្រីមានចំណងជើងថា A Handbook For My Lover ត្រូវបានបោះពុម្ពផ្សាយនៅក្នុងប្រទេសឥណ្ឌា ដោយរោងពុម្ព Harper Collins ។

**អំពីកម្មវិធី Prudential Eye Programme**

ដោយបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៨ ដោយ លោក David Ciclitira និងលោកស្រី Serenella Ciclitira និងដោយបានទទួលការឧបត្ថម្ភពីសំណាក់ក្រុមហ៊ុនព្រូដិនសល ជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងគ្រប់គ្រងទ្រព្យសកម្មឈានមុខគេនៅក្នុងតំបន់ កម្មវិធី Prudential Eye Programme គឺជាការផ្តួចផ្តើមមួយ ដែលសំដៅលើកកម្ពស់ទេពកោសល្យសិល្បៈ ។ កម្មវិធីនេះមានគោលបំណង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្នែកសិល្បៈនៅតំបន់ដែលមានការខ្វះខាត សំដៅផ្តល់ឲ្យសិល្បករនូវវេទិកាគាំទ្រ និងការទទួលស្គាល់ ដែលពួកគេត្រូវការដើម្បីអភិវឌ្ឍអាជីពរបស់ខ្លួន ។ កម្មវិធីនេះ ព្យាយាមកសាងបណ្តាញ និងឱកាសសម្រាប់សិល្បករ និងវិចិត្រសាល តាមរយៈភាពជាដៃគូយុទ្ធសាស្ត្រ និងការរៀបចំវេទិកាចម្រុះ ។

គម្រោងដែលរៀបចំដោយកម្មវិធី Prudential Eye Programme កាលពីអតីតកាល រួមមានជាអាទិ៍ ព្រឹត្តិការណ៍ Korean Eye (ឆ្នាំ២០០៩-២០១២) ព្រឹត្តិការណ៍ Indonesian Eye (ឆ្នាំ២០១១) ព្រឹត្តិការណ៍ Hong Kong Eye (ឆ្នាំ២០១៣) ព្រឹត្តិការណ៍ Prudential Malaysian Eye (ឆ្នាំ២០១៤) និងព្រឹត្តិការណ៍ Prudential Singapore Eye (ឆ្នាំ២០១៥) ដែលសុទ្ធសឹងជាព្រឹត្តិការណ៍តាំងពិព័រណ៍អន្តរជាតិ ដែលផ្តល់ឱកាសឲ្យសិល្បករថ្មីៗនៅក្នុងតំបន់អាស៊ីបានតាំងបង្ហាញស្នាដៃរបស់ខ្លួន ។ មកទល់បច្ចុប្បន្ន កម្មវិធីនេះបានរៀបចំព្រឹត្តិការណ៍តាំងពិព័រណ៍ចំនួន២៣ នៅទូទាំងពិភពលោក ដែលបានចូលរួមទស្សនាដោយមនុស្សជាង២លាននាក់ ។

នៅក្នុងខែមករា ឆ្នាំ២០១៤ កម្មវិធី Prudential Eye Programme បានបង្កើតកម្មវិធីប្រគល់រង្វាន់ Prudential Eye Awards នៅក្នុងប្រទេសសិង្ហបុរី ដើម្បីផ្តល់រង្វាន់ដល់ស្នាដៃសិល្បករថ្មីៗនៅទូទាំងទ្វីបអាស៊ី និងរៀបចំសម្ពោធកម្មវិធីអប់រំប្រកបដោយភាពច្នៃប្រឌិតជាមួយនឹងក្រុមប្រឹក្សានៃប្រទេសអង់គ្លេស ។

PRUDENTIAL
EYE AWARDS
CONTEMPORARY ASIAN ART

ព្រឹត្តិការណ៍តាំងពិព័រណ៍ចុងក្រោយបំផុត របស់កម្មវិធី Prudential Eye Programme គឺព្រឹត្តិការណ៍ Thailand Eye presented by Prudential ដែលបានរៀបចំឡើងនៅវិចិត្រសាល Saatchi ទីក្រុងឡុងដ៍ ចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៥ ដល់ថ្ងៃទី២ ខែមករា ឆ្នាំ២០១៦ ។ ព្រឹត្តិការណ៍តាំងពិព័រណ៍ ក៏នឹងត្រូវធ្វើឡើងនៅមជ្ឈមណ្ឌលវប្បធម៌សិល្បៈ ទីក្រុងបាងកក ចាប់ពីថ្ងៃទី១៧ ខែមីនា ដល់ថ្ងៃទី២៦ ខែមិថុនា ២០១៦ ផងដែរ ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ www.prudentialthailandeye.com ។

## អំពីមជ្ឈមណ្ឌលសិល្បៈសហសម័យ Parallel

មជ្ឈមណ្ឌលសិល្បៈសហសម័យ Parallel គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញមួយ ដែលបានផ្តល់ការគាំទ្រដល់សិល្បករថ្មីៗនៅទូទាំងពិភពលោក ។ មជ្ឈមណ្ឌលនេះត្រូវបានបង្កើតឡើងដោយលោក David Ciclitira និងលោកស្រី Serenella Ciclitira ដែលជាអ្នកប្រមូលទិញសិល្បៈ ជាពិសេសសិល្បៈសហសម័យ អស់រយៈពេលជាងពីរទសវត្សរ៍មកហើយ ។ ដោយសារក្តីស្រឡាញ់ចំពោះការធ្វើដំណើរ និងការស្វែងរកទេពកោសល្យសិល្បៈថ្មីៗ លោក David Ciclitira និងលោកស្រី Serenella Ciclitira បានស្វែងយល់ថា សិល្បករវ័យក្មេងនៅក្នុងតំបន់ជាច្រើននៃទ្វីបអាស៊ី មិនសូវទទួលបានការគាំទ្រ នឹងមានត្រូវបានគេកត់សម្គាល់នោះឡើយ ។ ដូច្នេះ ដើម្បីជួយអភិវឌ្ឍអាជីពរបស់សិល្បករក្នុងតំបន់អាស៊ី ពួកគាត់បានផ្តួចផ្តើមរៀបចំកម្មវិធី Global Eye Programme ជាកម្មវិធីបណ្តុះទេពកោសល្យសិល្បៈនៅទូទាំងពិភពលោក ដែលទទួលការឧបត្ថម្ភដោយក្រុមហ៊ុនព្រូដិនសល ។

## អំពីសាជីវកម្មព្រូដិនសលអាស៊ី (Prudential Corporation Asia)

សាជីវកម្មព្រូដិនសលអាស៊ី គឺជាអង្គភាពអាជីវកម្មមួយ របស់ក្រុមហ៊ុនព្រូដិនសល ភីអិលស៊ី នៃចក្រភពអង់គ្លេស* ដែលគ្របដណ្តប់លើប្រតិបត្តិការសេវាធានារ៉ាប់រងអាយុជីវិតរបស់ក្រុមហ៊ុននៅក្នុងតំបន់អាស៊ី និងអាជីវកម្មគ្រប់គ្រងទ្រព្យសម្បត្តិឈ្មោះថា Eastspring Investments ។ សាជីវកម្មព្រូដិនសលអាស៊ី មានទីស្នាក់ការនៅក្នុងទីក្រុងហុងកុង។

ក្រុមហ៊ុនព្រូដិនសល គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតឈានមុខគេមួយនៅលើពិភពលោក ដែលមានប្រតិបត្តិការនៅ ១២ប្រទេស ក្នុងតំបន់អាស៊ី រួមមាន កម្ពុជា ចិន ហុងកុង ឥណ្ឌា ឥណ្ឌូនេស៊ី កូរ៉េ ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី តៃវ៉ាន់ ថៃ និង វៀតណាម ។ ក្រុមហ៊ុនព្រូដិនសលមានបណ្តាញចែកចាយច្រើន និងរឹងមាំ ដែលផ្តល់ជូននូវផលិតផលសន្សំ វិនិយោគ និង ការពារជាច្រើនជម្រើស សម្រាប់បំពេញតាមតំរូវការផ្សេងៗគ្នារបស់អតិថិជនក្នុងតំបន់អាស៊ី ។

* ក្រុមហ៊ុនព្រូដិនសល ភីអិលស៊ី ត្រូវបានចុះបញ្ជីនៅប្រទេសអង់គ្លេស និងប្រទេសវេលស៍ ហើយសម្ព័ន្ធក្រុមហ៊ុនរបស់ខ្លួន គឺជាក្រុមសេវាកម្មហិរញ្ញវត្ថុឈានមុខគេនៅលើពិភពលោក ។ ក្រុមហ៊ុនមានអាយុកាល ១៦៦ឆ្នាំមកហើយ និងមានទ្រព្យសកម្មក្រោមការគ្រប់គ្រង ចំនួន ៥០៥ពាន់លានផោន (គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥) ។ ក្រុមហ៊ុនព្រូដិនសល ភីអិលស៊ី មិនជាប់ពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន Prudential Financial Inc ដែលជាក្រុមហ៊ុនមួយ មានទីតាំងពាណិជ្ជកម្មគោលនៅក្នុងសហរដ្ឋអាមេរិកនោះឡើយ ។

## អំពីព្រឹត្តិការណ៍ "សប្តាហ៍សិល្បៈសឹង្ហបុរី" (Singapore Art Week)

កម្មវិធី Prudential Eye Awards ឆ្នាំ២០១៦ គឺជាផ្នែកមួយព្រឹត្តិការណ៍ "សប្តាហ៍សិល្បៈសឹង្ហបុរី" ដែលប្រព្រឹត្តិទៅពីថ្ងៃទី ១៦ ដល់ ២៤ ខែមករា ឆ្នាំ២០១៦ ។ ព្រឹត្តិការណ៍នេះជា គំនិតផ្តួចផ្តើមរបស់ក្រុមប្រឹក្សាសិល្បៈជាតិសឹង្ហបុរី ក្នុងភាពជាដៃគូជាមួយក្រុមប្រឹក្សាទេសចរណ៍សឹង្ហបុរី និងក្រុមប្រឹក្សាភិបាលអភិវឌ្ឍន៍សេដ្ឋកិច្ចសឹង្ហបុរី ដោយមានគោលបំណងពង្រឹងកិត្តិនាមរបស់ប្រទេសសិង្ហបុរី ថាជាគោលដៅសិល្បៈឈានមុខគេនៅអាស៊ី ។ ព្រឹត្តិការណ៍នេះ មានរយៈពេលប្រាំបួនថ្ងៃ

ដែលរួមបញ្ចូលការតាំងបង្ហាញរូបភាពសិល្បៈ នៅតាមទីតាំងជាច្រើនទូទាំងប្រទេសសិង្ហបុរី រួមទាំងសារមន្ទីរ មជ្ឈមណ្ឌលសិល្បៈ និងទីតាំងមិនយកកម្រៃផ្សេងទៀត ។

ផ្ដល់ជូនសម្រាប់សាធារណជនសិង្ហបុរី និងភ្ញៀវអន្តរជាតិ ព្រឹត្តិការណ៍ "សប្ដាហ៍សិល្បៈសឹង្ហបុរី" ផ្ដល់បទពិសោធន៍សិល្បៈដែលមានគុណភាពខ្ពស់ ដូចជាកម្មវិធីតាំងពិព័រណ៍សិល្បៈ ការបើកសម្ពោធវិចិត្រសាល ការតាំងបង្ហាញ ព្រឹត្តិការណ៍កំសាន្តការបង្ហាញម៉ូដជាសាធារណៈ និងវេទិកាពិភាក្សាអំពីសិល្បៈ និងវប្បធម៌ ។ ដោយរួមបញ្ចូលសិល្បៈលើសពីសិល្បៈសម័យបច្ចុប្បន្ន ពោលគឺគ្រប់ទម្រង់នៃសិល្បៈទាំងទំនើប និងបុរាណ ព្រឹត្តិការណ៍ "សប្ដាហ៍សិល្បៈសឹង្ហបុរី" មានគោលដៅលើកកម្ពស់វិស័យសិល្បៈ និងរៀបចំកម្មវិធីសិល្បៈ និងកំសាន្តប្រកបដោយភាពច្នៃប្រឌិត ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ www.artweek.sg ។

**អំពីក្រុមហ៊ុន Marina Bay Sands Pte Ltd**

សណ្ឋាគារ Marina Bay Sands គឺជាទិសដៅអាជីវកម្ម សម្រាកលំហែ និងកម្សាន្តនាំមុខគេនៅតំបន់អាស៊ី ។ សណ្ឋាគារមាន ទីតាំងសម្រាប់ការប្រជុំ និងតាំងពិព័រណ៍ធំទូលាយ និងប្រកបដោយភាពបត់បែន បន្ទប់សណ្ឋាគារ និងបន្ទប់ស្វ៊ីត (suite) ចំនួន ២.៥៦០ ដំបូល Sands SkyPark ផ្សារទំនើបល្អបំផុតនៅអាស៊ី ភោជនីយដ្ឋានដែលមានមេចុងភៅល្បីៗលំដាប់ពិភពលោក និងផ្លាហ្សាសម្រាប់រៀបចំព្រឹត្តិការណ៍នៅខាងក្រៅផងដែរ ។ រោងមហោស្រពរបស់សណ្ឋាគារ មានចំនួនពីរ ដែលផ្ដល់ជូននូវទស្សនីយភាពសម្ដែងសំបូរបែប រួមមានទាំងការបង្ហាញដោយក្រុម Broadway ដ៏ល្បីឈ្មោះលើពិភពលោកទៀតផង ។ បន្ថែមពីនេះ សណ្ឋាគារ Marina Bay Sands គឺជាទីតាំងនៃសារមន្ទីរ ArtScience ដែលតែងមានការតាំងបង្ហាញជាអចិន្ត្រៃយ៍ ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ www.marinabaysands.com ។

**អំពីសារមន្ទីរ ArtScience**

សារមន្ទីរ ArtScience ដែលស្ថិតនៅក្នុងសណ្ឋាគារ Marina Bay Sands គឺជាមជ្ឈមណ្ឌលវប្បធម៌ឈានមុខគេនៅតំបន់អាស៊ីអាគ្នេយ៍ ដែលផ្ដោតលើអន្តរទំនាក់ទំនងរវាងសិល្បៈ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវប្បធម៌ ។ ដោយមានសាលតាំងបង្ហាញចំនួន២១ និងទំហំផ្ទៃដីសរុប ៥ម៉ឺន ហ្វីតការ៉េ អគាររាងដូចផ្កាឈូករបស់សារមន្ទីរនេះ ធ្លាប់ត្រូវបានជ្រើសរើសជាទីតាំងសម្រាប់ការតាំងពិព័រណ៍ធំៗ នូវស្នាដៃរបស់សិល្បករល្បីៗក្នុងសតវត្សរ៍ទី២០ នេះ ដូចជា លោក Salvador Dali លោក Andy Warhol និងលោក Vincent Van Gogh ជាដើម ព្រមទាំងត្រូវបានជ្រើសរើសជាទីតាំងសម្រាប់ការតាំងពិព័រណ៍ធំៗជាច្រើនអំពីប្រវត្តិសាស្ត្រវិទ្យាសាស្ត្រទៀតផង ។

**អំពីវិចិត្រសាល Saatchi**

វិចិត្រសាល Saatchi ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៨៥ ដោយមានគោលបំណងនាំសិល្បៈសហសម័យទៅដល់ទស្សនិកជនកាន់តែច្រើន តាមរយៈការបង្កើតវេទិកាច្នៃប្រឌិត សម្រាប់សិល្បករថ្មីៗបង្ហាញស្នាដៃរបស់ពួកគេ ។ ក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ បើយោងតាមការស្ទង់មតិរបស់កាសែតសិល្បៈ The Art Newspaper អំពីចូលរួមក្នុងកម្មវិធីតាំងពិព័រណ៍អន្តរជាតិ វិចិត្រសាល Saatchi បានរៀបចំការតាំងពិព័រណ៍ដែលមានអ្នកចូលទស្សនាច្រើនបំផុតរហូតដល់១០ដង ក្នុងចំណោមការតាំងពិព័រណ៍ដែលមានអ្នកចូលទស្សនាច្រើនបំផុតទាំង១៥ នៅទីក្រុងឡុងដ៍ ។ យោងតាមការវិភាគរបស់ Museum Analytics វិចិត្រសាលនេះ ក៏ជាប់ចំណាត់ជា វិចិត្រសាលមួយក្នុងចំណោមសារមន្ទីរដែលមានមនុស្សចូលចិត្តច្រើនបំផុតនៅលើ Facebook និង Twitter ទូទាំងពិភពលោកផងដែរ ។ វេបសាយរបស់វិចិត្រសាល Saatchi បានក្លាយទៅជាវេទិកាជួបជុំគ្នាជាសកលមួយ សម្រាប់រាល់បុគ្គលដែលចាប់អារម្មណ៍នឹងសិល្បៈសហសម័យ។